ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងមុខងារសាធារណៈសូមជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា អាស្រ័យដោយផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ១៩ ការជ្រើសរើសក្របខណ្ឌថ្មីសម្រាប់ឆ្នាំ២០២០ឲ្យចូលបំរើការងារជាមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានផ្អាកជាបណ្តោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី។ ក្នុងន័យនេះ កន្លងមកក្រសួងមុខងារសាធារណៈក៏បានធ្វើនិរាករណ៍លើសេចក្តីសម្រេចស្តីពីការជ្រើសរើសមន្ត្រីថ្មីក្នុងឆ្នាំ២០២០នេះផងដែរ។

អាស្រ័យហេតុនេះ ក្រសួងមុខងារសាធារណៈសូមសាធារណជនមេត្តាយោគយល់ចំពោះការលំបាករួមជាបណ្តោះអាសន្នក្នុងកាលៈទេសៈបច្ចុប្បន្ននេះ និងសូមចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ សំដៅការពារសុខភាព និងសុខមាលភាពសាធារណៈ រួមចំណែកបន្តរក្សាការពាររឹងមាំនូវសុខសន្តិភាព ការអភិវឌ្ឍ និងអនាគតរុងរឿងរបស់ប្រទេសជាតិ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ✓

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh